# ការពិនិត្យវាយតម្លៃលេខសម្រាប់សិស្ស Year 1

**ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ**



## តើពិនិត្យវាយតម្លៃលេខសម្រាប់សិស្ស Year 1 គឺជាអ្វី?

ការពិនិត្យវាយតម្លៃលេខសម្រាប់សិស្ស Year 1 (Year 1 Number Screening Check) គឺជាការវាយតម្លៃទូទាំងរដ្ឋដ៏ខ្លីមួយ ដែលប្រាប់គ្រូអំពីរបៀបដែលកូនរបស់អ្នកកំពុងរីកចម្រើនក្នុងការយល់ដឹងអំពីលេខក្នុងដំណាក់កាលដំបូង។ ការពិនិត្យវាយតម្លៃនេះ សង្កេតមើលពីរបៀបដែលកូនរបស់អ្នកអាចស្គាល់លេខ លំដាប់លេខ ការរាប់ចំនួន ប្រៀបធៀប និងបូក ហើយនិងដក។

កូនរបស់អ្នកនឹងអង្គុយជាមួយគ្រូម្នាក់ ហើយនឹងត្រូវបានសួរឱ្យឆ្លើយប្រហែល 30 សំណួរ។ ការពិនិត្យវាយតម្លៃនេះជាធម្មតាចំណាយពេល **10 ទៅ 15** នាទី។ Year 1 Number Screening Check ត្រូវបានរចនាឡើងយ៉ាងប្រុងប្រយ័ត្ន ដើម្បីកុំឱ្យកូនរបស់អ្នកមានភាពតានតឹង។ ប្រសិនបើកូនរបស់អ្នកមានការខំពុះពារ គ្រូនឹងបញ្ឈប់ការត្រួតពិនិត្យនោះ។

គោលបំណងសំខាន់នៃ Year 1 Number Screening Check គឺផ្ដល់ព័ត៌មានដល់គ្រូរបស់កូនអ្នក ដែលនឹងអនុញ្ញាតឱ្យពួកគេរៀបចំផែនការសម្រាប់ការរៀនសូត្ររបស់កូនអ្នក។ កុមារ Year 1 ទាំងអស់នឹងត្រូវបានវាយតម្លៃដោយឡែកពីគ្នាដោយគ្រូម្នាក់។

| |
|---|
| សូមទាក់ទងសាលារៀនរបស់អ្នក ប្រសិនបើអ្នកមានចម្ងល់ណាមួយអំពី Year 1 Number Screening Check។ |

## តើអ្វីទៅការយល់ដឹងអំពីលេខ?

ការយល់ដឹងអំពីលេខគឺជាសមត្ថភាពក្នុងការយល់ដឹង ទាក់ទិនទៅនឹង ហើយធ្វើការជាមួយលេខប្រកបដោយប្រសិទ្ធភាពដើម្បីចូលរួមក្នុងជីវិតប្រចាំថ្ងៃ និងការយល់ដឹងពីពិភពលោកជុំវិញដោយមានន័យសមហេតុផល។ កុមារខ្លះពិបាកយល់ដឹងអំពីលេខ ដូច្នេះវាមានសារៈសំខាន់ណាស់ដែលកុមារទាំងនេះត្រូវបានកំណត់អត្តសញ្ញាណយ៉ាងឆាប់រហ័ស។ តាមវិធីនេះ គ្រូអាចរៀបចំផែនការសម្រាប់ការគាំទ្រជាក់លាក់ណាមួយដែលពួកគេប្រហែលជាត្រូវការ។

## ហេតុអ្វីបានជាការយល់ដឹងមានសារៈសំខាន់?

មូលដ្ឋានគ្រឹះដ៏ល្អក្នុងការយល់ដឹងអំពីលេខ ជួយឱ្យកូនរបស់អ្នកយល់ដឹងអំពីគោលគំនិតគណិតវិទ្យាដ៏ស្មុគស្មាញបន្ថែមទៀតនៅក្នុងឆ្នាំក្រោយៗនៃសាលាបឋមសិក្សា និងវិទ្យាល័យ។

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ដើម្បីទាក់ទងសាលារៀន សូមទូរសព្ទទៅលេខ 131 450 ប្រាប់ការីទូរសព្ទនូវភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យពួកគេទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។